**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាចោះជំរំប្រធានមេក្រុមភាយឬទ្ធិ**
**គិរីរម្យ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩**

# ព្រះជាម្ចាស់លើកលែងទោសឲ្យយើងលុះត្រាតែយើងកែប្រែចិត្តគំនិត

**អត្ថបទទី១៖ យ៉ូស៊ូអា ៥,៩ក.១០-១២**

ពេលនោះ ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកយ៉ូស៊ូអាថា៖ «ថ្ងៃនេះ យើងដកគសេចក្ដីអាម៉ាស់ចេញឆ្ងាយពីអ្នករាល់គ្នាហើយ គឺសេចក្ដីអាម៉ាស់ដែលអ្នករាល់គ្នាធ្លាប់រងនៅស្រុកអេស៊ីប»។ យស ៥,៩ក

**អត្ថបទទី២៖ កូរិនថូសទី២ ៥,១៧-២១**

នៅក្នុងអង្គព្រះគ្រីស្ដ ព្រះជាម្ចាស់បានសម្រុះសម្រួលមនុស្សលោកឲ្យជានានឹងព្រះអង្គ ដោយមិនប្រកាន់ទោសគេឡើយ។ ព្រះអង្គក៏ដាក់ព្រះបន្ទូលនៃការសម្រុះសម្រួលនេះមកក្នុងយើងដែរ។ ២ករ ៥,១៩

**ដំណឹងល្អ៖ លូកា ១៥,១-៣.១១-៣២**

កូនពៅជម្រាបឪពុកថា "លោកឪពុក កូនបានប្រព្រឹត្តអំពើបាបខុសនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ កូនក៏បានប្រព្រឹត្តអំពើបាបខុសនឹងលោកឪពុកដែរ មិនគួរឲ្យលោកឪពុករាប់ខ្ញុំនេះជាកូនទៀតទេ"។ លក ១៥,២១

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងស្ដាប់រឿងកូនពៅវង្វេង ជាអត្ថបទមួយដែលយើងចង់មើលនិងយល់អំពីរបៀបដែលព្រះជាម្ចាស់ស្រឡាញ់យើង។ របៀបយើងជូនកាលយើងដូចជាកូនពៅវង្វេង ជូនកាលយើងវង្វេងមែនយើងធ្វើឲ្យឪពុកម្ដាយពិបាកចិត្ត យើងធ្វើឲ្យមិត្តភក្តិយើងពិបាកចិត្ត យើងធ្វើឲ្យលោកគ្រូអ្នកគ្រូ អ្នកដឹកនាំ ធ្វើឲ្យលោកឪពុក អ្នកនៅក្នុងសង្គមពិបាកចិត្ត។ ពេលនោះណែនាំឲ្យយើងសប្បាយ យើងដើរលេងសប្បាយ ប៉ុន្តែអ្នកគេទទួលខុសត្រូវ អ្នកដែលគេស្រឡាញ់យើង គេពិបាកចិត្ត។ ក្នុងអត្ថបទនេះ ឪពុកគាត់ពិបាកចិត្តពីថ្ងៃដែលកូនគាត់បានចេញ និងពេលកូនទៅដើរលេង ពេលកូនស៊ីផឹកចាយលុយអស់ហើយ នៅពេលនោះគាត់ភ្ញាក់និងយល់ថាជីវិតរបស់គាត់បានធ្វើខុសអស់ហើយ។ ប៉ុន្តែគាត់ភ្ញាក់ពេលគាត់អស់ហើយ ពេលគាត់មានលុយចាយគាត់អត់សូវរវីរវល់ទេ តែពេលគាត់អស់ហើយពេលគាត់កំពុងធ្វើអ្នកបម្រើគេ ចិញ្ចឹមជ្រូកឲ្យគេ ចំណីជ្រូកក៏ស៊ីមិនបាន គាត់ចាប់ផ្ដើមគិតធ្វើយ៉ាងម៉េចដើម្បីឲ្យខ្ញុំមានម្ហូបអាហារវិញ។ ដោយសារអ្វីដែលណែនាំឲ្យគាត់ត្រឡប់ទៅផ្ទះវិញ គឺដោយសារគាត់ឃ្លានជិតដាច់ពោះស្លាប់ ដូច្នេះគាត់សុខចិត្តធ្វើដំណើរទៅវិញ។ ប៉ុន្តែឲ្យយើងចាប់អារម្មណ៍ នៅក្នុងចិត្តគំនិតរបស់គាត់មានពីរចំណុច **គឺទីមួយ គាត់យល់ថាគាត់បានធ្វើខុសនឹងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ និងទីពីរ គាត់បានធ្វើនឹង**

**សេចក្តីស្រឡាញ់របស់ឪពុកគាត់។** ដូច្នេះគាត់កំពុងភ័យខ្លាចប៉ុន្តែយល់ថាដាក់ខ្លួនដើម្បីសុំឲ្យឪពុកទទួលវិញទៅជាអ្នកបម្រើតូចតាចមួយក៏បាន ឲ្យមានម្ហូបអាហារបរិភោគ។

អ្វីដែលកើតឡើងគឺប្លែក ដោយសារនៅពេលគាត់ទៅដល់ផ្ទះឪពុកគាត់រត់ដើម្បីស្វាគមន៍គាត់ គាត់មិនទាន់ឆ្លងខ្លោងទ្វារផងឪពុកដែលកំពុងទន្ទឹងរង់ចាំគាត់ ពីមួយខែពីរខែបីខែកន្លងមកហើយ ពេលគាត់ឮសម្លេងកូនគាត់ត្រឡប់មកវិញគាត់មកទទួលស្វាគមន៍ និងណែនាំឲ្យកូននេះបីដូចមានជីវិតថ្មីភ្លាម ជប់លៀងឲ្យគាត់ណែនាំឲ្យមានកិត្តិយសសារជាថ្មី ដោយសារឪពុកសប្បាយចិត្តបាត់កូនរកឃើញកូនវិញ។ ដូច្នេះ យើងយល់នេះរបៀបព្រះជាម្ចាស់ ប៉ុន្តែយើងឃើញកូនច្បងច្រណែន គាត់អន់ចិត្ត ទោះបីប្អូនបង្កើតត្រឡប់មកវិញគាត់អត់មានសេចក្តីសុខសោះ ដោយសារគាត់ឆ្ងល់មូលហេតុអ្វីឪពុកមិនដែលឲ្យអ្វីសោះទៅគាត់ ប៉ុន្តែសម្រាប់ប្អូនដែលធ្វើបាបឪពុកយ៉ាងខ្លាំងគាត់ឲ្យយ៉ាងច្រើន នេះជាសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ស្រឡាញ់យើងអត់មានកំរិត អត់មានព្រំដែន យើងវាស់មិនបានទេ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់សម្រាប់មនុស្សគឺស្មើៗគ្នា។ ប៉ុន្តែ នៅពេលយើងធ្វើខុសកុំឲ្យយើងយល់វង្វេង កុំឲ្យយើងយល់ច្រឡំ យើងធ្វើខុសឲ្យយើងធ្វើយ៉ាងម៉េចដើម្បីកែប្រែគំនិត ប្រសិនបើកូនពៅនេះអត់មានគំនិតចង់កែប្រែគំនិតប្រហែលឪពុកគាត់មិនអាចទទួលបានទេ។

យើងត្រូវការរស់នៅត្រឹមត្រូវ ទាំងនៅក្នុងជីវិតជាគ្រីស្តបរិស័ទជាមួយព្រះជាម្ចាស់ដែលលើកលែងទោសឲ្យយើង ទាំងជីវិតរបស់យើងជាពលរដ្ឋជាកូនម្នាក់ដែលរស់នៅក្នុងសង្គម។ កុំឲ្យយើងគិតថាព្រះជាម្ចាស់លើកលែងទោសឲ្យខ្ញុំ ដូច្នេះខ្ញុំធ្វើអ្វីក៏បាន។ សម្រាប់យើងដែលជាប្រធានមេក្រុមកាយឫទ្ធិ មានន័យថាយើងជាអ្នកដឹកនាំ ដឹកនាំមេកាយឫទ្ធិផ្សេងៗ ដឹកនាំកូនក្មេងដើម្បីឲ្យគេរស់នៅយ៉ាងត្រឹមត្រូវ នៅក្នុងសីលធម៌ ឲ្យគេទៅជាកូន អនាគតយុវជននិងជាមនុស្សពេញលេញដែលរស់នៅយ៉ាងត្រឹមត្រូវនៅក្នុងសង្គម។ ម្សិលមិញនៅសាលាសន្តប្រាំង់ស្វ័រមានចោលចូលលួចម៉ាស៊ីនព្រីន យើងមានកាំមេរ៉ាសុវត្ថិភាពដូច្នេះយើងបានចាប់គាត់ដោយសារមានគេស្គាល់។ មានគេប្រាប់ខ្ញុំថា យើងជាគ្រីស្តបរិស័ទលើកលែងទោសឲ្យគាត់ យើងជាគ្រីស្តបរិស័ទយើងលើកលែងទោសឲ្យគាត់ដូចព្រះជាម្ចាស់លើកលែងទោស ប្រសិនបើគាត់ចង់មានជីវិតថ្មី។ ប៉ុន្តែមិនអាចគេចខ្លួនពីយុត្តិធម៌របស់មនុស្ស បើយើងបានធ្វើខុសច្បាប់នៅក្នុងសង្គម ទោះបីព្រះជាម្ចាស់លើកលែងទោសឲ្យយើងនៅក្នុងជម្រៅដួងចិត្តរបស់យើងពិតមែន តែយើងត្រូវទទួលខុសត្រូវនៅមុខច្បាប់របស់សង្គម។ យើងជាគ្រីស្តបរិស័ទយើងលើកលែងទោសឲ្យគេ ប៉ុន្តែយើងមិនអាចធ្វើជំនួសយុត្តិធម៌និងច្បាប់នៅក្នុងសង្គម។

នៅពេលនេះ យើងត្រូវការយល់ថាព្រះជាម្ចាស់ណែនាំឲ្យយើងទៅជាប្រធានមេក្រុមកាយឬទ្ធិដើម្បីដឹកនាំមេក្រុមទាំងអស់ ដើម្បីដឹកនាំកូនកាយឬទ្ធិបន្តទៀត ឲ្យគេរស់នៅនៅក្នុងរបៀបត្រឹមត្រូវ ទាំងនៅក្នុងជីវិតធម្មតាជាមួយឪពុកម្តាយ ជាមួយធម្មជាតិ ជាមួយព្រះជាម្ចាស់ ជាមួយមិត្តភក្តិ និងឲ្យគេទៅជាកូនល្អ ពលរដ្ឋត្រឹមត្រូវនៅក្នុងសង្គម ឲ្យចេះគោរពគ្រប់វិន័យ គ្រប់ច្បាប់របស់សង្គម។ យើងដឹងថា ច្បាប់នីមួយៗមិនមែនរំខានយើង ប៉ុន្តែណែនាំឲ្យយើងរួមរស់ជាមួយគ្នា។ សម្រាប់យើងជាក្រុមកាយឬទ្ធិ យើងមានពាក្យសច្ចារបស់យើងគឺសំខាន់ណាស់ធ្វើយ៉ាងម៉េចគោរពវិន័យរបស់ព្រះជាម្ចាស់ ស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះយេស៊ូបានស្រឡាញ់យើង។ ព្រះយេស៊ូស្រឡាញ់យើងរហូតដល់បូជាជីវិត ណែនាំឲ្យយើងរស់នៅយ៉ាងត្រឹមត្រូវនៅក្នុងសង្គម ដើម្បីឲ្យសង្គមរបស់យើងអាចមានសុខដុមរមនា ដោយសារយើងចេះគោរពគ្នាទៅវិញទៅមក គោរពគ្នាទៅវិញទៅមក លុះត្រាតែយើងគោរពវិន័យនិងច្បាប់ដែលមាននៅក្នុងសង្គម។

យើងអរព្រះគុណព្រះជាម្ចាស់ ដែលបានជ្រើសរើសយើងទៅជាមេក្រុមកាយឬទ្ធិ ទៅជាយុវជនយុវនារី ដែលធ្វើដំណើរនៅក្នុងជីវិតរួមជាមួយព្រះអង្គ និងយើងទទួលស្គាល់ថាពិតមែនព្រះជាម្ចាស់ស្រឡាញ់យើង ពិតមែនព្រះជាម្ចាស់លើកលែងទោសឲ្យយើង លុះត្រាតែយើងយកចិត្តទុកដាក់ស្រឡាញ់ យកចិត្តទុកដាក់ស្តាប់ធម្មវិន័យ និងយកចិត្តទុកដាក់រស់នៅជាមនុស្សដែលខិតខំកែប្រែចិត្តគំនិតធ្វើជាមនុស្សសុចរិតជានិច្ច។ យើងអធិដ្ឋានសម្រាប់មេក្រុមកាយឬទ្ធិនៅក្នុងភូមិភាគភ្នំពេញទាំងអស់ យើងអធិដ្ឋានសម្រាប់គ្រួសារយើងនីមួយៗ ហើយយើងដឹងថាបន្តិចទៀត ខ្ញុំនឹងបិទការអធិដ្ឋាន២៤ម៉ោងសម្រាប់ព្រះជាម្ចាស់ ឲ្យពេលវេលានេះមានផ្លែយ៉ាងច្រើនសម្រាប់ព្រះសហគមន៍យើង ប្រទេសយើង និងសម្រាប់ពិភពលោកយើង។ អាម៉ែន៕